លេខ / N°: C2

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
**Kingdom of Cambodia**
**Nation Religion King**
**Royaume du Cambodge**
**Nation Religion Roi**

អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា
Extraordinary Chambers in the Courts of Cambodia

**ការិយាល័យសហចៅក្រមស៊ើបអង្កេត**
**Office of the Co-Investigating Judges**
**Bureau des Co-juges d'instruction**
**សំណុំរឿងព្រហ្មទណ្ឌ**
**Criminal Case File /Dossier pénal**
**លេខ/No:003/07-09-2009-ECCC-OCIJ**

# ដីកាបង្គាប់ឱ្យនាំខ្លួន
# Arrest Warrant
# Mandat d'amener

ឯកសារដើម
ORIGINAL DOCUMENT/DOCUMENT ORIGINAL
ថ្ងៃ ខែ ឆ្នាំ ទទួល (Date of receipt/date de reception): 05 / 06 / 2015
ម៉ោង (Time/Heure) : 10:00
មន្ត្រីទទួលបន្ទុកសំណុំរឿង /Case File Officer/L'agent chargé du dossier: SANN RADA

យើង **Mark B. Harmon** សហចៅក្រមស៊ើបអង្កេតអន្តរជាតិនៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា("អ.វ.ត.ក")

**បានឃើញ** ច្បាប់ស្តីពីការបង្កើតអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ចុះថ្ងៃទី ២៧ ខែ តុលា ឆ្នាំ ២០០៤("ច្បាប់ស្តីពីការបង្កើត អ.វ.ត.ក")។

**បានឃើញ** *ដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរលើកទី២ របស់សហព្រះរាជអាជ្ញា* ដាក់នៅថ្ងៃទី ០៧ ខែ កញ្ញា ឆ្នាំ ២០០៩("ដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរ")[1]។

**បានឃើញ** *ដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរបន្ថែមរបស់សហព្រះរាជអាជ្ញាស្តីពីទីតាំងឧក្រិដ្ឋកម្មនានាទាក់ទងនឹងសំណុំរឿង ០០៣* ដាក់នៅថ្ងៃទី ៣១ ខែ តុលា ឆ្នាំ ២០១៤("ដីកាសន្និដ្ឋានបញ្ជូនឱ្យស៊ើបសួរបន្ថែម"[2]។

---

[1]សំណុំរឿង ០០៣ ឯកសារ D1 *ដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរលើកទី២របស់សហព្រះរាជអាជ្ញា ទាក់ទងនឹងកងទ័ពបដិវត្តន៍កម្ពុជា* ថ្ងៃទី ២០ ខែ វិច្ឆិកា ឆ្នាំ ២០០៨។ សំណុំរឿង ០០៣ ឯកសារ D1/1 *ការជូនដំណឹងអំពីការដាក់ដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរលើកទី២ របស់សហព្រះរាជអាជ្ញាអន្តរជាតិស្តីទី* ថ្ងៃទី០៧ ខែកញ្ញា ឆ្នាំ២០០៩ ។

[2]សំណុំរឿង ០០៣ ឯកសារ D120 *ដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរបន្ថែមរបស់សហព្រះរាជអាជ្ញាអន្តរជាតិស្តីពីទីតាំងឧក្រិដ្ឋកម្មនានាទាក់ទងនឹងសំណុំរឿង ០០៣* ថ្ងៃទី ៣១ ខែ តុលា ឆ្នាំ ២០១៤។

**បានឃើញ** កិច្ចស៊ើបសួរទាក់ទងនឹងការចោទប្រកាន់អំពីការរំលោភបំពាន**ក្រមព្រហ្មទណ្ឌ ឆ្នាំ ១៩៥៦ ឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ និងអំពើបំពារបំពានយ៉ាងធ្ងន់ធ្ងរទៅលើអនុសញ្ញាទីក្រុងហ្សឺណែវ ចុះថ្ងៃទី ១២ ខែ សីហា ឆ្នាំ ១៩៤៩** ជាបទល្មើសដែលមានចែង និងផ្តន្ទាទោសតាមមាត្រា ៣(ថ្មី), ៥, ៦, ២៩ និង ៣៩ នៃច្បាប់ស្តីពីការបង្កើត អ.វ.ត.ក និងមាត្រា៥០០, ៥០១, ៥០៣, ៥០៥, ៥០៦, ៥០៧ និង៥០៨ នៃក្រមព្រហ្មទណ្ឌឆ្នាំ ១៩៥៦។

**បានឃើញ** *ដីកាបង្គាប់ឱ្យនាំខ្លួន មាស មុត* ដាក់នៅថ្ងៃទី ១១ ខែ ធ្នូ ឆ្នាំ ២០១៤[3]។

**បានឃើញ** *ដីកាសម្រេចដាក់ មាស មុត ឱ្យស្ថិតក្រោមការពិនិត្យដោយកំបាំងមុខ* ដាក់នៅថ្ងៃទី ០៣ ខែ មីនា ឆ្នាំ ២០១៥ ("ដីកាសម្រេចដាក់ឱ្យស្ថិតក្រោមការពិនិត្យ")[4]។

**បានឃើញ**វិធាន ១១, ២១, ២២, ៤២, ៤៥, ៥៥(៥), ៦៣ និង៧២ នៃវិធានផ្ទៃក្នុងរបស់អ.វ.ត.ក ("វិធានផ្ទៃក្នុង")។

**បានឃើញ**កំណត់ហេតុនៃករណីខ្វែងយោបល់គ្នា ចុះបញ្ជីនៅថ្ងៃទី ០៧ និង ថ្ងៃទី ២២ ខែ កុម្ភៈ ឆ្នាំ ២០១៣ និង ១៧ ខែ កក្កដា ឆ្នាំ ២០១៤។

**បានឃើញ**ព័ត៌មានដូចខាងក្រោមទាក់ទងនឹងអត្តសញ្ញាណរបស់ មាស មុត៖

- ឈ្មោះ៖ **មាស មុត** ហៅ អាចារ្យ នេន
- ថ្ងៃខែឆ្នាំកំណើត៖ ១៩៣៨
- ស្រុកកំណើត៖ ភូមិពោធិ៍ ឃុំស្រែក្នុង ស្រុកឈូក ខេត្តកំពត
- សញ្ជាតិ៖ ខ្មែរ
- ទីលំនៅបច្ចុប្បន្ន៖ ភូមិតាសាញ ជើង ស្រុកសំឡូត ខេត្តបាត់ដំបង
- ឈ្មោះប្រពន្ធ៖ ខុំ(Khom) (ស្លាប់) និង ខា(Kha)
- ឈ្មោះកូន៖ ភាព និងវុធ
- មានរូបថតដូចបានភ្ជាប់ជាមួយ។

[3]សំណុំរឿង ០០៣ ឯកសារ C1 *ដីកាបង្គាប់ឱ្យនាំខ្លួន មាស មុត* ថ្ងៃទី ១១ ខែ ធ្នូ ឆ្នាំ ២០១៤។

[4]សំណុំរឿង ០០៣ ឯកសារ D128 *ដីកាសម្រេចដាក់ មាស មុត ឱ្យស្ថិតក្រោមការពិនិត្យដោយកំបាំងមុខ* ថ្ងៃទី ០៣ ខែ មីនា ឆ្នាំ ២០១៥។

**បានឃើញ**ថា នៅថ្ងៃទី ០៣ ខែ មីនា ឆ្នាំ ២០១៥ សហចៅក្រមស៊ើបអង្កេតអន្តរជាតិ បានដាក់ មាស មុត ឲ្យស្ថិតក្រោមការពិនិត្យ*ដោយកំបាំងមុខ*[5] ពីបទរំលោភបំពានក្រមព្រហ្មទណ្ឌឆ្នាំ ១៩៥៦ ឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ និងអំពើបំពារបំពានយ៉ាងធ្ងន់ធ្ងរទៅលើអនុសញ្ញាទីក្រុងហ្សឺណែវ ចុះថ្ងៃទី ១២ ខែ សីហា ឆ្នាំ ១៩៤៩[6]។

**បានឃើញ**ថា អនុលោមតាមវិធានផ្ទៃក្នុង ៤២ សហចៅក្រមស៊ើបអង្កេតអន្តរជាតិ អាចចេញដីកាបង្គាប់ឲ្យនាំខ្លួនជនត្រូវចោទ ទោះបីជាជននោះនៅក្នុង ឬនៅក្រៅដែនដីនៃព្រះរាជាណាចក្រកម្ពុជាក៏ដោយ។

**បានឃើញ**ថា អនុលោមតាមវិធានផ្ទៃក្នុង ៦៣ សហចៅក្រមស៊ើបអង្កេតអន្តរជាតិ អាចសម្រេចឃុំខ្លួនជនត្រូវចោទជាបណ្ដោះអាសន្នក្រោយពេលមានសវនាការតទល់គ្នា។

អាស្រ័យហេតុនេះ បង្គាប់ នគរបាលយុត្តិធម៌ ឲ្យអនុវត្តដីកាបង្គាប់ឲ្យនាំខ្លួននេះជាបន្ទាន់។

នគរបាលយុត្តិធម៌ អនុលោមតាមវិធាន ៤៥ មិនត្រូវចូលទីលំនៅដ្ឋានរបស់ មាស មុត មុនម៉ោង ៦ ព្រឹក ឬក្រោយម៉ោង ៦ ល្ងាច ហើយ នគរបាលយុត្តិធម៌ ត្រូវជូនដំណឹង សហចៅក្រមស៊ើបអង្កេតអន្តរជាតិ អំពីការលំបាកណាមួយនៅក្នុងការបំពេញភារកិច្ចរបស់ខ្លួន។

នគរបាលយុត្តិធម៌ ត្រូវនាំ មាស មុត មកបង្ហាញខ្លួននៅចំពោះមុខ សហចៅក្រមស៊ើបអង្កេតអន្តរជាតិ សម្រាប់សវនាការតទល់គ្នាដើម្បីពិចារណាចេញដីកាបង្គាប់ឲ្យឃុំខ្លួនបណ្ដោះអាសន្នអនុលោមតាមវិធានផ្ទៃក្នុង ៦៣។

ប្រសិនបើ ដោយសារកាលៈទេសៈនានា មាស មុត មិនអាចត្រូវបាននាំខ្លួនមកបង្ហាញនៅចំពោះមុខ សហចៅក្រមស៊ើបអង្កេតអន្តរជាតិ បានភ្លាមៗទេ គាត់ត្រូវដាក់ឲ្យជាប់ឃុំខ្លួនបណ្ដោះអាសន្ននៅក្នុងមន្ទីរឃុំឃាំងបណ្ដោះអាសន្នរបស់ អ.វ.ត.ក នៅពេលណាដែលអាចធ្វើទៅបាន ហើយត្រូវនាំខ្លួនមកបង្ហាញនៅចំពោះមុខ សហចៅក្រមស៊ើបអង្កេតអន្តរជាតិ ឲ្យបានឆាប់បំផុតតាមដែលអាចធ្វើទៅបាន។

---

[5] ដីកាសម្រេចដាក់ឲ្យស្ថិតក្រោមការពិនិត្យ។

[6] សំណុំរឿង ០០៣ ឯកសារ D128.1 *ការជូនដំណឹងអំពីបទចោទប្រកាន់ប្រឆាំង មាស មុត* ថ្ងៃទី ០៣ ខែ មីនា ឆ្នាំ ២០១៥។

មាស មុត មានសិទ្ធិដូចខាងក្រោមអនុលោមតាមវិធានផ្ទៃក្នុង៖

- សិទ្ធិមានមេធាវីការពារតាមការជ្រើសរើសរបស់គាត់ ដូចមានចែងនៅក្នុងវិធានផ្ទៃក្នុង ១១, ២១, ២២ និង ៦៣ និងបទបញ្ញារដ្ឋបាលដែលចូលជាធរមាន។

- សិទ្ធិនៅស្ងៀមមិនឆ្លើយនឹងសំណួរ អនុលោមតាមវិធានផ្ទៃក្នុង ២១(១)(ឃ)។

- សិទ្ធិស្នើឱ្យមានពេលវេលាគ្រប់គ្រាន់ដើម្បីរៀបចំការការពារខ្លួន អនុលោមតាមវិធានផ្ទៃក្នុង ៦៣(១)(ក)(ខ) ដែលក្នុងករណីនេះ សហចៅក្រមស៊ើបអង្កេតអន្តរជាតិ មិនត្រូវបង្គាប់ឱ្យឃុំខ្លួនបណ្ដោះអាសន្នភ្លាមៗទេ ហើយអាចសម្រេចតាមរយៈដីកាមានសំអាងហេតុ ឃុំខ្លួន មាស មុត សម្រាប់រយៈពេលមួយមិនលើសពីប្រាំពីរថ្ងៃ។

- សិទ្ធិបញ្ចេញយោបល់ដោយផ្ទាល់ខ្លួន ឬតាមរយៈមេធាវីរបស់គាត់ នៅក្នុងអំឡុងពេលសវនាការនេះ ដូចមានចែងនៅក្នុងវិធានផ្ទៃក្នុង ៦៣(១)(ក)។

- សិទ្ធិត្រូវបានដោះលែងឱ្យមានសេរីភាពប្រសិនបើមិនមានសេចក្ដីសម្រេចបង្គាប់ឱ្យឃុំខ្លួនបណ្ដោះអាសន្ន ដូចមានចែងនៅក្នុងវិធានផ្ទៃក្នុង ៦៣(១)(ក)។

- សិទ្ធិប្ដឹងឧទ្ធរណ៍ចំពោះដីកាសម្រេចឃុំខ្លួនបណ្ដោះអាសន្នទៅអង្គបុរេជំនុំជម្រះ អនុលោមតាមវិធានផ្ទៃក្នុង ៦៣(៤) ប្រសិនបើមានដីកាសម្រេចបែបនោះ។

- សិទ្ធិទទួលបានប្រយោជន៍នានាពីបទប្បញ្ញត្តិទាក់ទងនឹងការដោះលែងឱ្យនៅក្រៅឃុំ និងលក្ខខណ្ឌដាក់ឱ្យស្ថិតនៅក្រោមការត្រួតពិនិត្យតាមផ្លូវតុលាការ ដូចមានចែងនៅក្នុងវិធានផ្ទៃក្នុង ៦៤ និង ៦៥។

- សិទ្ធិពិគ្រោះជាមួយមេធាវី មុនពេលគាត់ត្រូវបានសួរចម្លើយនៅក្នុងដំណាក់កាលណាមួយនៃការស៊ើបអង្កេតរបស់តុលាការ។

ប្រសិនបើគាត់ត្រូវដាក់ឱ្យជាប់ឃុំខ្លួនបណ្ដោះអាសន្ន ដោយសារថា គាត់មិនអាចត្រូវបាននាំខ្លួនមកបង្ហាញនៅចំពោះមុខ សហចៅក្រមស៊ើបអង្កេតអន្តរជាតិ បានភ្លាមៗទេនោះ គាត់មានសិទ្ធិដូចខាងក្រោមអនុលោមតាមវិធានផ្ទៃក្នុង ៥១៖

- សិទ្ធិស្នើសុំជួបមេធាវី ហើយមេធាវីនោះនឹងត្រូវបានជូនដំណឹងអំពីសំណើនេះភ្លាមៗ តាមមធ្យោបាយទាំងអស់ដែលមាន និង

- សិទ្ធិជួបមេធាវីបែបនោះ ឬក៏ប្រសិនបើចំណុចនេះមិនអាចធ្វើបាន គឺត្រូវជួបមេធាវីម្នាក់ដែលផ្តល់ជូនដោយអង្គភាពគាំពារការការពារក្តី ដោយជួបបានរយៈពេលអតិបរមាណ ៣០ (សាបសិប) នាទីមុនពេលគាត់ត្រូវបានបង្ហាញខ្លួននៅចំពោះមុខសហចៅក្រមស៊ើបអង្កេតអន្តរជាតិ។ មេធាវីរូបនេះត្រូវមានសិទ្ធិមានវត្តមាននៅក្នុងអំឡុងពេលនៃការឃុំខ្លួនគ្រប់គ្រងដោយនគរបាល អាស្រ័យតាមលក្ខខណ្ឌតម្រូវរដ្ឋបាលរបស់មន្ទីរឃុំឃាំងបណ្តោះអាសន្ន។

សហចៅក្រមស៊ើបអង្កេតអន្តរជាតិ ស្នើថា អាជ្ញាធរមានសមត្ថកិច្ចទាំងអស់ ត្រូវផ្តល់ជំនួយគ្រប់បែបយ៉ាងជូននគរបាលយុត្តិធម៌ ប្រសិនបើចាំបាច់ក្នុងការអនុវត្តដីកាបង្គាប់ឱ្យនាំខ្លួននេះ។

ភ្នំពេញ ថ្ងៃទី ០៤ ខែ មិថុនា ឆ្នាំ ២០១៥

*E.C.C.C*C.E.T.C* CO-INVESTIGATING JUDGES

**លោកស្រី Mark B. Harmon**

**សហចៅក្រមស៊ើបអង្កេតអន្តរជាតិ**

**International Co- Investigating Judge**

**Co-juge d'instruction International**